ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការបង្កើតបន្ថែមគណនី និងអនុគណនី នៃប្លង់គណនេយ្យសាធារណៈ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៤៨ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតបន្ថែម គណនី និងអនុគណនីនៃប្លង់គណនេយ្យសាធារណៈ ដែលមានឈ្មោះ និងលេខសម្គាល់ដូចខាងក្រោម÷

**១.**គណនី "គណនីចរន្តនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា" (លេខ ១១១៧) ដែលស្ថិតនៅជំពូក "ធនាគារ" (លេខ ១១)។

**២.**គណនី "គណនីចរន្តនៅធនាគារអេស៊ីលីដា ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល" (លេខ ១១២៦) ដែលស្ថិតនៅជំពូក "ធនាគារ" (លេខ ១១)។

**៣.**គណនី "គណនីចរន្តនៅធនាគារកាណាឌីយ៉ា ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល" (លេខ ១១៣៦) ដែលស្ថិតនៅជំពូក "ធនាគារ" (លេខ ១១)។

**៤.**អនុគណនី “ប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល-គាវកាលិកនៅរតនាគារ” (លេខ ១២០៥៣) ដែលស្ថិតនៅក្នុងគណនី “ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ” (លេខ ១២០៥) នៃជំពូក “ប្រាក់បញ្ញើរបស់រដ្ឋ និងសមូហភាពសាធារណៈ នៅរតនាគារ” (លេខ ១២)។

**៥.**អនុគណនី “ប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន-គាវកាលិកនៅរតនាគារ” (លេខ ១២០៥៤) ដែលស្ថិតនៅក្នុងគណនី “ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ” (លេខ ១២០៥) នៃជំពូក “ប្រាក់បញ្ញើរបស់រដ្ឋ និងសមូហភាពសាធារណៈនៅរតនាគារ” (លេខ ១២)។

**៦.**អនុគណនី “បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ” (លេខ ១៥០៥៧) ដែលស្ថិតនៅក្នុងគណនី “ចំណាយរង់ចាំដោះស្រាយ” (លេខ ១៥០៥) នៃជំពូក “គណនីត្រូវទទួល” (លេខ ១៥)។

**៧.**អនុគណនី “ប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល-គាវកាលិក” (លេខ ៤៤០៥៣) ដែលស្ថិតនៅក្នុងគណនី “ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល” (លេខ ៤៤០៥) នៃជំពូក “ប្រាក់បញ្ញើរបស់រដ្ឋ និងសមូហភាពសាធារណៈ” (លេខ ៤៤)។

**៨.**អនុគណនី “ប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន-គាវកាលិក” (លេខ ៤៤០៥៤) ដែលស្ថិតនៅក្នុងគណនី “ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល” (លេខ ៤៤០៥) នៃជំពូក “ប្រាក់បញ្ញើរបស់រដ្ឋ និងសមូហភាពសាធារណៈ” (លេខ ៤៤)។

**៩.**គណនី “បុរេប្រទានបានទទួល” (លេខ ៤៧១០) ដែលស្ថិតនៅជំពូក “គណនីចម្លង ឬ គណនីរង់ចាំ” (លេខ ៤៧)។ គណនីនេះ ត្រូវប្រើជំនួសគណនីលេខ ១១០៨។

**១០.**អនុគណនី “ភាគទានសម្រាប់របបសន្តិសុខសង្គម” (លេខ ៦២០១១) ដែលស្ថិតនៅក្នុងគណនី “អត្ថប្រយោជន៍របបសន្តិសុខសង្គម” (លេខ ៦២០១) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

**១១.**អនុគណនី “ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល” (លេខ ៦២០១២) ដែលស្ថិតនៅក្នុងគណនី “អត្ថប្រយោជន៍របបសន្តិសុខសង្គម” (លេខ ៦២០១) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

**១២.**អនុគណនី “ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន” (លេខ ៦២០១៣) ដែលស្ថិតនៅក្នុងគណនី “អត្ថប្រយោជន៍របបសន្តិសុខសង្គម” (លេខ ៦២០១) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

**១៣.**អនុគណនី “ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់បេឡាជាតិរបបសន្តិសុខសង្គម” (លេខ ៦២០១៤) ដែលស្ថិតនៅក្នុងគណនី “អត្ថប្រយោជន៍របបសន្តិសុខសង្គម” (លេខ ៦២០១) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

**១៤.**អនុគណនី “អត្ថប្រយោជន៍របបសន្តិសុខសង្គមផ្សេងៗ” (លេខ ៦២០១៨) ដែលស្ថិតនៅក្នុងគណនី “អត្ថប្រយោជន៍របបសន្តិសុខសង្គម” (លេខ ៦២០១) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

**១៥.**គណនី “ឧបត្ថម្ភលើគាវកាលិក” (លេខ ៦២០៧) ដែលស្ថិតនៅក្នុងជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

**១៦.**អនុគណនី “ឧបត្ថម្ភលើការថែទាំសុខភាព” (លេខ ៦២០៧១) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើគាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

**១៧.**អនុគណនី “ឧបត្ថម្ភមាតុភាព” (លេខ ៦២០៧២) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើគាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

១៨.អនុគណនី “ឧបត្ថម្ភមរណភាព” (លេខ ៦២០៧៣) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើតាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

១៩.អនុគណនី “ឧបត្ថម្ភនិវត្តជន” (លេខ ៦២០៧៤) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើតាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

២០.អនុគណនី “ឧបត្ថម្ភជនបាត់បង់សម្បទាវិជ្ជាជីវៈ ឬ សមត្ថភាពការងារ” (លេខ ៦២០៧៥) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើតាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

២១.អនុគណនី “ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក” (លេខ ៦២០៧៦) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើតាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

២២.អនុគណនី “ឧបត្ថម្ភគ្រោះថ្នាក់ការងារ និងទព្វលភាព” (លេខ ៦២០៧៧) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើតាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

២៣.អនុគណនី “ឧបត្ថម្ភតាវកាលិកផ្សេងៗ” (លេខ ៦២០៧៨) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភលើតាវកាលិក” (លេខ ៦២០៧) នៃជំពូក “អត្ថប្រយោជន៍សង្គម” (លេខ ៦២)។

២៤.អនុគណនី “ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់តាវកាលិក” (លេខ ៧៥០១៥) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភធនពីថ្នាក់ជាតិ” (លេខ ៧៥០១) នៃជំពូក “ការឧបត្ថម្ភ និងអំណោយ” (លេខ ៧៥)។

២៥.គណនី “ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ” (លេខ ៧៥២០) ដែលស្ថិតនៅក្នុងជំពូក “ការឧបត្ថម្ភ និងអំណោយ” (លេខ ៧៥)។

២៦.អនុគណនី “ឧបត្ថម្ភធនពីមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត” (លេខ ៧៥២០១) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ” (លេខ ៧៥២០) នៃជំពូក “ការឧបត្ថម្ភ និងអំណោយ” (លេខ ៧៥)។

២៧.អនុគណនី “ឧបត្ថម្ភធនពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ” (លេខ ៧៥២០២) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ” (លេខ ៧៥២០) នៃជំពូក “ការឧបត្ថម្ភ និងអំណោយ” (លេខ ៧៥)។

២៨.អនុគណនី “ឧបត្ថម្ភធនពីមូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ” (លេខ ៧៥២០៣) ដែលស្ថិតនៅក្នុងគណនី “ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ” (លេខ ៧៥២០) នៃជំពូក “ការឧបត្ថម្ភ និងអំណោយ” (លេខ ៧៥)។

២៩.គណនី “ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម” (លេខ ៧៧០៦) ដែលស្ថិតនៅក្នុងជំពូក “ផលផ្សេងៗ និងផលពិសេស” (លេខ ៧៧)។

៣០.អនុគណនី “ភាគទានបានទទួល សម្រាប់ហានិភ័យការងារ” (លេខ ៧៧០៦១) ដែលស្ថិតនៅក្នុងគណនី “ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម” (លេខ ៧៧០៦) នៃជំពូក “ផលផ្សេងៗ និងផលពិសេស” (លេខ ៧៧)។

៣១.អនុគណនី “ភាគទានបានទទួល សម្រាប់ធានារ៉ាប់រងសុខភាព” (លេខ ៧៧០៦២) ដែលស្ថិតនៅក្នុងគណនី “ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម” (លេខ ៧៧០៦) នៃជំពូក “ផលផ្សេងៗ និងផលពិសេស” (លេខ ៧៧)។

៣២.អនុគណនី “ភាគទានបានទទួល សម្រាប់សោធន” (លេខ ៧៧០៦៣) ដែលស្ថិតនៅក្នុងគណនី “ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម” (លេខ ៧៧០៦) នៃជំពូក “ផលផ្សេងៗ និងផលពិសេស” (លេខ ៧៧)។

**ប្រការ២.-**

ប្រព្រឹត្តិកម្មនៃគណនី និងអនុគណនី÷

**១.**គណនី “គណនីចរន្តនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា” (លេខ ១១១៧) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយជាសាច់ប្រាក់នៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានទទួលជាសាច់ប្រាក់ ឬ ដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយ ជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រ ដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើ ដែលកំពុងមាននៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។

**ចំណាំ÷** គណនីនេះ ចែកចេញជាអនុគណនីចរន្តនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជាជាប្រាក់រៀល និងអនុគណនីចរន្តនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក។

**២.**គណនី “គណនីចរន្តនៅធនាគារអេស៊ីលីដា ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល” (លេខ ១១២៦) ដែលស្ថិតនៅជំពូក “ធនាគារ” (លេខ ១១)។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានទទួលជាសាច់ប្រាក់ ឬ ដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយ ជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រ ដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើ ជាប្រាក់ដុល្លារអាមេរិក ដែលកំពុងមាននៅធនាគារអេស៊ីលីដា។

**ចំណាំ÷**
- គណនីនេះ ចែកចេញជាអនុគណនីទៅតាមលេខកូដរបស់រាជធានី ខេត្ត នៃចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ការកត់ត្រានៅក្នុងគណនីនេះជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា និងអមដោយប្រាក់ដុល្លារអាមេរិក
- នៅដំណាច់ឆ្នាំ សមតុល្យជាប្រាក់រៀល ដែលបានពីការគណនាជាបន្តបន្ទាប់ត្រូវកែតម្រូវឱ្យស្មើនឹងចំនួនទឹកប្រាក់ជារៀល ដែលបានមកពីសមតុល្យជាប្រាក់ដុល្លារអាមេរិកគុណនឹងអត្រាប្តូរប្រាក់នៅដំណាច់ឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា។ លម្អៀងទឹកប្រាក់រវាងសមតុល្យជាប្រាក់រៀល ដែលបានពីការគណនាជាបន្តបន្ទាប់នឹងសមតុល្យជាប្រាក់រៀល

ដែលបានពីការគណនាពីសមតុល្យជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជានៅថ្ងៃគណនា ត្រូវចាត់ទុកជាចំណូលថវិកា ឬ ជាចំណាយថវិកា ដោយពុំមានសលាកបត្របង់ចំណូលថវិកា ឬ ការបោះផ្សាយអាណត្តិបើកប្រាក់ទេ។

៣.គណនី "គណនីចរន្តនៅធនាគារកាណាឌីយ៉ា ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល" (លេខ ១១៣៦) ដែលស្ថិតនៅជំពូក "ធនាគារ" (លេខ ១១)។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានទទួលជាសាច់ប្រាក់ ឬ ដោយបង្វែរ និងបានពីការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយ ជាសាច់ប្រាក់ ឬ ដោយបង្វែរ និងការទូទាត់របស់សភាផាត់ទាត់ជាមួយមូលប្បទានបត្រ ដែលបានបោះផ្សាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើ ជាប្រាក់ដុល្លារអាមេរិក ដែលកំពុងមាននៅធនាគារកាណាឌីយ៉ា។

**ចំណាំ÷** - គណនីនេះ ចែកចេញជាអនុគណនីទៅតាមលេខកូដរបស់រាជធានី ខេត្តនៃចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា

- ការកត់ត្រានៅក្នុងគណនីនេះជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា និងអមដោយប្រាក់ដុល្លារអាមេរិក
- នៅដំណាច់ឆ្នាំសមតុល្យជាប្រាក់រៀល ដែលបានពីការគណនាជាបន្តបន្ទាប់ត្រូវកែតម្រូវឱ្យស្មើនឹងចំនួនទឹកប្រាក់ជារៀល ដែលបានមកពីសមតុល្យជាប្រាក់ដុល្លារអាមេរិកគុណនឹងអត្រាប្តូរប្រាក់នៅដំណាច់ឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា។ លម្អៀងទឹកប្រាក់រវាងសមតុល្យជាប្រាក់រៀលដែលបានពីការគណនាជាបន្តបន្ទាប់នឹងសមតុល្យជាប្រាក់រៀល ដែលបានពីការគណនាពីសមតុល្យ ជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់របស់រតនាគារជាតិនៃកម្ពុជានៅថ្ងៃគណនា ត្រូវចាត់ទុកជាចំណូលថវិកា ឬ ជាចំណាយថវិកា ដោយពុំមានសលាកបត្របង់ចំណូលថវិកា ឬ ការបោះផ្សាយអាណត្តិបើកប្រាក់ទេ។

៤.អនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល-តាវកាលិកនៅរតនាគារ" (លេខ ១២០៥៣) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយប្រាក់បញ្ញើនៅរតនាគារ សម្រាប់បើកផ្តល់តាវកាលិកនៃអតីតមន្ត្រីរាជការស៊ីវិល។

ការកត់ត្រា÷

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ចំណូល នៃគណនីប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនៅរតនាគារ

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយ ពីគណនីប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនៅរតនាគារ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើ សម្រាប់បើកផ្តល់តាវកាលិករបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលកំពុងមាននៅរតនាគារ។

**បញ្ជាក់÷** គណនីលេខ ១២០៥៣ សម្រាប់ប្រើតែនៅក្នុងកិច្ចបញ្ជិកាគណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។

**៥.**អនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន-តាវកាលិក នៅរតនាគារ" (លេខ ១២០៥៤) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយប្រាក់បញ្ញើនៅរតនាគារ សម្រាប់បើកផ្តល់តាវកាលិកនៃអតីតយុទ្ធជន។

ការកត់ត្រា÷

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ចំណូលនៃគណនីប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជននៅរតនាគារ

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយ ពីគណនីប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជននៅរតនាគារ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើ សម្រាប់បើកផ្តល់តាវកាលិករបស់បេឡាជាតិអតីតយុទ្ធជន ដែលកំពុងមាននៅរតនាគារ។

**បញ្ជាក់÷** គណនីលេខ ១២០៥៤ សម្រាប់ប្រើតែនៅក្នុងកិច្ចបញ្ជិកាគណនេយ្យរបស់បេឡាជាតិអតីតយុទ្ធជន។

**៦.**អនុគណនី "បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ" (លេខ ១៥០៥៧) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទាន ដែលបានផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាព ដែលមានលក្ខណៈប្រហាក់ប្រហែល ដោយបញ្ចូលទៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពដែលមានលក្ខណៈប្រហាក់ប្រហែលទាំងនោះនៅរតនាគារ។

ការកត់ត្រា÷

ឥណពន្ធ :កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានផ្តល់ដោយបញ្ចូលទៅគណនីប្រាក់បញ្ញើ

ឥណទាន :កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទូទាត់ដោយកាត់ពីគណនីប្រាក់បញ្ញើ ឬ បង់ជាសាច់ប្រាក់

សមតុល្យ :ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលបានបញ្ចូលគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពដែលមានលក្ខណៈប្រហាក់ប្រហែល ហើយពុំទាន់បានទូទាត់។

**បញ្ជាក់÷** គណនីលេខ ១៥០៥៧ ប្រើសម្រាប់កត់ត្រានៅក្នុងកិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ។

**៧.**អនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល-តាវកាលិក" (លេខ ៤៤០៥៣) សម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល សម្រាប់តាវកាលិក។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលបានចំណាយពីប្រាក់បញ្ញើសម្រាប់តាវកាលិក

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណូលប្រាក់បញ្ញើសម្រាប់តាវកាលិកដែលបានពីក្រសួង ស្ថាប័ន

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយដែលបានទទួល

សមតុល្យ: ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល សម្រាប់តាវកាលិកកំពុងមាននៅរតនាគារ។

**បញ្ជាក់÷** គណនីលេខ ៤៤០៥៣ សម្រាប់ប្រើនៅក្នុងកិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ ហើយឆ្លុះបញ្ចាំងបញ្ច្រាសជាមួយអនុគណនីលេខ ១២០៥៣។

**៨.**អនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន-តាវកាលិក" (លេខ ៤៤០៥៤) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន សម្រាប់តាវកាលិក។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលបេឡាជាតិអតីតយុទ្ធជនបានចំណាយពីប្រាក់បញ្ញើសម្រាប់តាវកាលិក

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណូលប្រាក់បញ្ញើសម្រាប់តាវកាលិកដែលបានពីក្រសួង ស្ថាប័ន

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយដែលបានទទួល

សមតុល្យ: ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន សម្រាប់តាវកាលិកកំពុងមាននៅរតនាគារ។

**បញ្ជាក់÷** គណនីលេខ ៤៤០៥៤ សម្រាប់ប្រើនៅក្នុងកិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ ហើយឆ្លុះបញ្ចាំងបញ្ច្រាសជាមួយអនុគណនីលេខ ១២០៥៤។

**៩.**គណនី "បុរេប្រទានបានទទួល" (លេខ ៤៧១០) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទាន ដែលរដ្ឋបាលថ្នាក់ជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែល បានទទួលពីរតនាគារ ក្រសួង ស្ថាប័ន អង្គភាព យោងតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអាណាព្យាបាល ឬ អគ្គនាយកដ្ឋានរតនាគារជាតិ។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពប្រហាក់ប្រហែល និងរដ្ឋទេយ្យករបុរេប្រទានបានទូទាត់បុរេប្រទានបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែល និងរដ្ឋទេយ្យករបុរេប្រទានបានទទួលបុរេប្រទាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បុរេប្រទាន ដែលបានទទួលហើយពុំទាន់បានទូទាត់។

**ចំណាំ÷** - ប្រាក់បុរេប្រទាន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែលបានទទួល និងបានទូទាត់ ត្រូវឆ្លងកាត់គណនីប្រាក់បញ្ញើនៅរតនាគារ

ក្នុងគណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងគណនេយ្យរបស់អង្គភាពប្រហាក់ប្រហែល។

- គណនីប្រាក់បុរេប្រទាន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែលបានទទួល និងបានទូទាត់ ឆ្លុះបញ្ចាំងបញ្ច្រាសជាមួយគណនីចំណាយបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) នៅក្នុងគណនេយ្យរដ្ឋ ដែលប្រើប្រាស់ដោយរតនាគារ។

**១០.**អនុគណនី "ភាគទានសម្រាប់របបសន្តិសុខសង្គម" (លេខ ៦២០១១) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិលើការបង់ភាគទាន សម្រាប់របបសន្តិសុខសង្គមរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បុគ្គលិក កម្មករ និងនិយោជិត។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើការបង់ភាគទាន

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១១.**អនុគណនី "ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល" (លេខ ៦២០១២) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានឧបត្ថម្ភជូនបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល សម្រាប់បើកផ្តល់តាវកាលិកជូននិវត្តជន។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើការផ្តល់ឧបត្ថម្ភធន

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១២.**អនុគណនី "ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន" (លេខ ៦២០១៣) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានឧបត្ថម្ភជូនបេឡាជាតិអតីតយុទ្ធជន សម្រាប់បើកផ្តល់តាវកាលិកជូននិវត្តជន។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើការផ្តល់ឧបត្ថម្ភធន

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

១៣.អនុគណនី "ឧបត្ថម្ភរបបសន្តិសុខសង្គមសម្រាប់បេឡាជាតិរបបសន្តិសុខសង្គម" (លេខ ៦២០១៤) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានឧបត្ថម្ភជូនបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់បើកផ្តល់តាវកាលិក។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើការផ្តល់ឧបត្ថម្ភធន

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

១៤.អនុគណនី "អត្ថប្រយោជន៍របបសន្តិសុខសង្គមផ្សេងៗ" (លេខ ៦២០១៨) ឧបត្ថម្ភជូនអង្គភាពផ្សេងៗក្រៅពីអនុគណនីខាងលើ។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើការផ្តល់ឧបត្ថម្ភធន

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

១៥.គណនី "ឧបត្ថម្ភលើតាវកាលិក" (លេខ ៦២០៧) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិរបបសន្តិសុខសង្គម បានបើកផ្តល់តាវកាលិកជូននិវត្តជន កម្មករ និងនិយោជិត។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើការបើកផ្តល់តាវកាលិក

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ÷** គណនីនេះ ចែកចេញជាអនុគណនីឧបត្ថម្ភលើការថែទាំសុខភាព អនុគណនីឧបត្ថម្ភមាតុភាព អនុគណនីឧបត្ថម្ភមរណភាព អនុគណនីឧបត្ថម្ភនិវត្តជន អនុគណនីឧបត្ថម្ភជនបាត់បង់សម្បទាវិជ្ជាជីវៈ ឬ សមត្ថភាពការងារ អនុគណនីឧបត្ថម្ភអ្នកនៅក្នុងបន្ទុក អនុគណនីឧបត្ថម្ភគ្រោះថ្នាក់ការងារនិងទព្វលភាព និងអនុគណនីឧបត្ថម្ភតាវកាលិកផ្សេងៗ។

១៦.អនុគណនី "ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់តាវកាលិក" (លេខ ៧៥០១៥) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិរបបសន្តិសុខសង្គម ដែលបានពីក្រសួង ស្ថាប័ន សម្រាប់បើកផ្តល់តាវកាលិក។

ការកត់ត្រា÷

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានបន្ថយ

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានទទួលពីឧបត្ថម្ភធន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

១៧.គណនី "ឧបត្ថម្ភធនពីមូលនិធិថ្នាក់ជាតិ" (លេខ ៧៥២០) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបានពីមូលនិធិរបស់រដ្ឋបាលថ្នាក់ជាតិ។

ការកត់ត្រា÷

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានបន្ថយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅការិយលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ÷** គណនីនេះចែកចេញជាអនុគណនីឧបត្ថម្ភធនពីមូលនិធិអភិវឌ្ឍន៍របស់រាជធានី ខេត្ត អនុគណនីឧបត្ថម្ភធនពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុគណនីឧបត្ថម្ភធនពីមូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ។

១៨.គណនី "ភាគទានបានទទួល សម្រាប់របបសន្តិសុខសង្គម" (លេខ ៧៧០៦) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងរបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលបានពីការបង់ភាគទានរបស់និវត្តជន មន្ត្រីរាជការ និយោជិត និងនិយោជក។

ការកត់ត្រា÷

ឥណពន្ធ :-កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

-កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានបន្ថយ

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**ចំណាំ÷** គណនីនេះចែកចេញជា អនុគណនីភាគទានបានទទួលសម្រាប់ហានិភ័យការងារ អនុគណនីភាគទានបានទទួលសម្រាប់ធានារ៉ាប់រងសុខភាព និងអនុគណនីភាគទានបានទទួលសម្រាប់សោធន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ថ្ងៃចន្ទ ២រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ខែ ធ្នូ ឆ្នាំ២០១៨

**រដ្ឋបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

  *"ដើម្បីជូនជ្រាប"*
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពាក់ព័ន្ធ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រឹះស្ថានសាធារណៈរដ្ឋបាលពាក់ព័ន្ធ

  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ